**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ**

លេខៈ ...១០៧ ៨ស៧.. អកធ.បស្ត

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

## សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃការផ្គត់ផ្គង់សម្ភារសួរសុខទុក្ខសម្រាប់មន្ត្រីឧទ្យានុរក្ស ឆ្នាំ២០១៨

អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យបានជ្រាបថា អគ្គនាយកដ្ឋាននឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកផ្គត់ផ្គង់សម្ភារសួរសុខទុក្ខសម្រាប់មន្ត្រីឧទ្យានុរក្សឆ្នាំ២០១៨។

ក្រុមលទ្ធកម្មនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅនាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ (បន្ទប់បូកគោ ជាន់ទី២) ដែលមានអាសយដ្ឋាន អគារមេតេកតេជោ ដីឡូលេខ៥០៣ ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ (បន្ទប់បូកគោ ជាន់ទី២) ចាប់ពីថ្ងៃទី .០៤..... ខែ កក្កដា.....ឆ្នាំ២០១៨ តទៅ រៀងរាល់ម៉ោងធ្វើការ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង១០ម៉ោ០០. ថ្ងៃទី..៣១.... ខែកក្កដា.....ឆ្នាំ២០១៨។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ តាមអាសយដ្ឋានខាងលើ វេលាម៉ោង..១០.ម៉ោ០០.......ថ្ងៃទី..៣១....ខែ.កក្កដា........ឆ្នាំ២០១៨។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយក្រុមលទ្ធកម្មរបស់អគ្គនាយកដ្ឋាន ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ។

ថ្ងៃ សុក្រ ១១ កើត ខែ ទុ.សាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ...២៥...ខែ .កក្កដា..ឆ្នាំ២០១៨
អគ្គនាយក
និងជាប្រធានក្រុមលទ្ធកម្ម

**ចម្លងជូនៈ**
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
«អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ»
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ កាលប្បវត្តិ



អគារមេតេកតេជោ ជាន់ទី២ ដីឡូលេខ៥០៣ ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ E-mail: gdancp@moe.gov.kh